# វគ្គប្រជុំទី 2 អំពីភាគីពាក់ព័ន្ធនឹងច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024

ថ្ងៃទី 17 ខែមេសា ឆ្នាំ 2025

កិច្ចប្រជុំតាមអនឡាញ

ថ្ងៃទី 17 ខែមេសា ឆ្នាំ 2025

# ការរៀបចំសេវាបកប្រែផ្ទាល់មាត់

- **ការបកប្រែភាសាផ្ទាល់មាត់ត្រូវបានផ្តល់ជូនជាភាសា៖ EEspañol, Português, Kreyòl ayisyen, Kriolu, Tiếng Việt, 普通话, عربي, русский, ខ្មែរ, 한국어, français និងភាសាសញ្ញាអាមេរិកាំង (ASL)។**
  - To participate in English, click the “Interpretation” icon and select English.
  - Para entrar no canal em português, clique no ícone “Interpretation” e selecione “Portuguese”.
  - Si alguien desea interpretación en español, haga clic en “Interpretation” y seleccione “Spanish”.
  - Pou rantre nan chanèl kreyòl ayisyen an, klike sou ikòn “Interpretation” an epi chwazi “Haitian Creole”.
  - Pa partisipa na Kriolu, klika na íkone "Intirpretason" y silisiona "Cape Verdean Kriolu".
  - 要以普通话参加会议，请单击口语图标并选择 "Chinese”.
  - Để vào kênh bằng tiếng Việt, hãy nhấp vào biểu tượng “Interpretation” và chọn “Vietnamese”.
  - للمشاركة باللغة العربية اضغط على أيقونة "الترجمة الفورية" ثم اختر “Arabic“.
  - Чтобы принять участие на Русский языке, нажмите на ярлык «Устный перевод» и выберите “Russian”.
  - ដើម្បីចូលរួមជាភាសាខ្មែរ សូមចុច រូបតំណាងការបកប្រែ ហើយជ្រើសរើសភាសា “Khmer”។
  - 한국어로 참여하려면 "통역" 아이콘을 클릭하고 “Korean"를 선택하세요.
  - Pour participer en français, cliquez sur l’icône « Interprétation » puis choisissez « French ».

- **សូមនិយាយយឺតៗ។**
- **រាល់អ្នកចូលរួមទាំងអស់ត្រូវតែជ្រើសរើសបណ្តាញភាសាមួយ ទោះបីជាមើលបទបង្ហាញជាភាសាអង់គ្លេសក៏ដោយ។**



# របៀបវារៈនៃកិច្ចប្រជុំថ្ងៃនេះ

| | |
|---|---|
| ▪ ម៉ោង 1:00៖ | កិច្ចស្វាគមន៍ |
| ▪ ម៉ោង 1:05៖ | ទិដ្ឋភាពទូទៅនៃការបកប្រែផ្ទាល់មាត់ |
| ▪ ម៉ោង 1:10៖ | សុន្ទរកថាបើកកិច្ចប្រជុំ – Staci Rubin ស្នងការនាយកដ្ឋាននៃការចូលរួមជាសាធារណៈ (DPU) |
| ▪ ម៉ោង 1:15៖ | ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 - Katie Gronendyke ទីប្រឹក្សាគោលនយោបាយថាមពលស្អាត |
| ▪ ម៉ោង 1:35៖ | បទបង្ហាញរបស់ក្រសួងធនធានថាមពល (DOER) – Rick Collins ជានាយកផ្នែកផ្តល់ការអនុញ្ញាត និងកំណត់ទីតាំងផលិតថាមពលស្អាត |
| ▪ ម៉ោង 1:45៖ | សំណួរ និងចម្លើយខ្លីៗ |
| ▪ ម៉ោង 1:55៖ | សេចក្តីផ្តើមរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងផលិតថាមពល (EFSB) – Connor Tarr មេធាវីផ្នែកកំណត់ទីតាំង |
| ▪ ម៉ោង 2:05៖ | ពង្រាងសំណើសម្រាប់ការដាក់ស្នើទៅក្រុមប្រឹក្សាភិបាលកំណត់ទីតាំងផលិតថាមពល (EFSB) – Andy Greene នាយកផ្នែកកំណត់ទីតាំង |
| ▪ ម៉ោង 2:35៖ | សំណួរ និងចម្លើយ |
| ▪ ម៉ោង 2:50៖ | សម្រាក |
| ▪ ម៉ោង 3:05៖ | ទិដ្ឋភាពទូទៅនៃផ្ទាំងគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងផលិតថាមពល (EFSB) |
| ▪ ម៉ោង 3:10៖ | សំណួរ និងចម្លើយបើកចំហ |
| ▪ ម៉ោង 3:55៖ | សេចក្តីសង្ខេបឡើងវិញ |

# ការអនុវត្តរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល

- ពង្រាងសំណើ/វគ្គប្រជុំជាមួយភាគីពាក់ព័ន្ធ – **នានិទាឃរដូវឆ្នាំ 2025**
- សវនាការសាធារណៈស្តីពីបទប្បញ្ញត្តិដែលបានស្នើឡើង – **រដូវស្លឹកឈើជ្រុះឆ្នាំ 2025**
- ការប្រកាសឱ្យអនុវត្តបទប្បញ្ញត្តិ និងការណែនាំ – **ឆ្នាំ 2025 ដល់ដើមឆ្នាំ 2026**
- បទប្បញ្ញត្តិថ្មីៗ – **ថ្ងៃទី 1 ខែមីនា ឆ្នាំ 2026**
- ការដាក់សំណើសុំថ្មីៗ – **ថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2026**

# តម្រូវការថាមពលស្អាតនៅក្នុងរដ្ឋ Massachusetts

ថាមពលដែលផលិតដោយទួរប៊ីនខ្យល់ **180 MW** ត្រឹមឆ្នាំ 2025
**4,470 MW** នៃថាមពលពីពន្លឺព្រះអាទិត្យជាចរន្តជំនួសត្រឹមឆ្នាំ 2025

**3,650 MW** នៃថាមពលដែលផលិតដោយទួរប៊ីនខ្យល់ត្រឹមឆ្នាំ 2030
**8,360 MW** នៃថាមពលពីពន្លឺព្រះអាទិត្យជាចរន្តជំនួសត្រឹមឆ្នាំ 2030

**24 GW** នៃថាមពលដែលផលិតដោយទួរប៊ីនខ្យល់ត្រឹមឆ្នាំ 2050
**27+ GW** នៃថាមពលពីពន្លឺព្រះអាទិត្យជាចរន្តជំនួសត្រឹមឆ្នាំ 2050

## សមត្ថភាពក្នុងការផលិតអគ្គិសនីកកើតឡើងវិញនៅក្នុងរដ្ឋ

**113 MW** នៃសម្ថភាពក្នុងការផលិតដោយទួរប៊ីនខ្យល់ក្នុងឆ្នាំ 2022
**3,325 MW** នៃសមត្ថភាពថាមពលពីពន្លឺព្រះអាទិត្យជាចរន្តជំនួសក្នុងឆ្នាំ 2022

## ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (GHG)

ការបំភាយឧស្ម័ននៅកម្រិត**សូន្យ**ត្រឹមឆ្នាំ 2050

ឆ្នាំ 2021 · ឆ្នាំ 2022 · ឆ្នាំ 2023 · ត្រឹមឆ្នាំ 2025 · ត្រឹមឆ្នាំ 2030 · ត្រឹមឆ្នាំ 2050

## សមត្ថភាពផ្ទុកថាមពល

**550 MWh** នៃការផ្ទុកថាមពល ដែលបានដំឡើងគិតត្រឹមថ្ងៃទី 15 ខែកុម្ភៈ ឆ្នាំ 2023

គោលដៅនៃការផ្ទុកថាមពលក្នុងទំហំ **1,000 MWh** ត្រឹមឆ្នាំ 2025

ទំហំផ្ទុក **5.8 GW** ត្រឹមឆ្នាំ 2050

## បន្ទុកអគ្គិសនី

ត្រឹមឆ្នាំ 2035 ទំនងជាមានការកើនឡើងដល់ 50% បើធៀបនឹងសព្វថ្ងៃ (60 GWh ដល់ទំហំ 90+ GWh)

# បញ្ហាប្រឈមជាមួយនឹងនីតិវិធីអនុញ្ញាតដែលមានស្រាប់

- ដំណើរការអនុញ្ញាតដែលមានរយៈពេលយូរ មិនអាចព្យាករជាមុនបាន និងជួនកាលមានលក្ខណៈស្មុគស្មាញ ដែលៗ។
  - ពេលវេលាកំណត់មានភាពខុសគ្នាខ្លាំង ហើយគម្រោងមួយចំនួនបានចំណាយពេលរហូតដល់មួយទសវត្សរ៍ដើម្បីបញ្ចប់។
  - តាមប្រវត្តិពីដើមមក ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារផលិតថាមពល (EFSB) បានចំណាយពេលចន្លោះពី 1 ដល់ 4 ឆ្នាំ ដើម្បីផ្តល់ការអនុញ្ញាតឱ្យដល់ការសាងសង់ បន្ទាប់ពីរយៈពេលនោះ គម្រោងនៅតែត្រូវការលិខិតអនុញ្ញាតក្នុងមូលដ្ឋានផ្សេងៗគ្នា និងពីរដ្ឋទាំងអស់។
- ឱកាសសម្រាប់បណ្តឹងឧទ្ធរណ៍លើលិខិតអនុញ្ញាតដាច់ដោយឡែកនីមួយៗអាចបណ្តាលឱ្យមានការពន្យារពេលជាច្រើនឆ្នាំ។
- អ្នកនៅក្នុងសហគមន៍មានអារម្មណ៍ថា ជាញឹកញាប់ពួកគេមិនបានផ្តល់មតិយោបល់គ្រប់គ្រាន់ ឬប្រកបដោយឥទ្ធិពលទៅក្នុងការកំណត់ទីតាំងសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗនោះទេ។
- អ្នកនៅក្នុងសហគមន៍អាចមិនមានធនធានចាំបាច់ដើម្បីចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការអនុញ្ញាតទេ។
- **រដ្ឋ Massachusetts នឹងមិនបំពេញតាមផែនកំណត់កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (GHG) របស់យើងដោយគ្មានការកែទម្រង់ទេ។**

# គណៈកម្មការទទួលបន្ទុកការកំណត់ទីតាំង និងការអនុញ្ញាតសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថាមពល

- ស្នងការត្រូវបានបង្កើតឡើងតាមបទបញ្ជាប្រតិបត្តិលេខ 620
- តម្រូវឱ្យផ្ដល់ដំបូន្មានដល់អភិបាលស្ដីពីៈ
  1. **ការពន្លឿនការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតប្រកបដោយភាពប្រុងប្រយ័ត្នតាមរយៈការកំណត់ទីតាំង និងការអនុញ្ញាតដែលមានការកែទម្រង់**តាមលក្ខណៈដែលអនុលោមតាមលក្ខខណ្ឌតម្រូវផ្លូវច្បាប់ជាធរមាន និងផែនការថាមពលស្អាត និងអាកាសធាតុ។
  2. **ការសម្រួលសម្រួលឱ្យមានការផ្ដល់មតិយោបល់ពីសហគមន៍** ទៅក្នុងការកំណត់ទីតាំង និងការអនុញ្ញាតចំពោះហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត និង
  3. **ការធានាថាអត្ថប្រយោជន៍ពីការផ្លាស់ប្ដូរទៅប្រើថាមពលស្អាតត្រូវបានចែករំលែកប្រកបដោយសមភាព**ក្នុងចំណោមប្រជាជនរស់នៅ Commonwealth។
- វគ្គនៃកិច្ចប្រជុំដោយស្ដាប់មតិសាធារណៈចំនួនពីរដែលបានធ្វើឡើង ហើយទទួលបានមតិសាធារណៈជាង 1,500 មតិ។
- ការណែនាំដែលបានផ្ញើជូនអភិបាល Healey កាលពីថ្ងៃទី 29 ខែមីនា ឆ្នាំ 2024។
- ការណែនាំរបស់ស្នងការត្រូវបានទទួលយកជាផ្លូវការយ៉ាងទូលំទូលាយដោយត្រូវបានអនុវត្តជាច្បាប់តាមរយៈ *ច្បាប់ស្ដីពីការលើកកម្ពស់បណ្ដាញថាមពលស្អាត ការលើកកម្ពស់សមភាព និងការការពារអ្នកបង់ថ្លៃថាមពលប្រើប្រាស់* (ច្បាប់ស្ដីពីអាកាសធាតុឆ្នាំ 2024) ដែលត្រូវបានចុះហត្ថលេខាដោយអភិបាល Healey កាលពីខែវិច្ឆិកា ឆ្នាំ 2024។

# ការអនុញ្ញាតរួមរបស់រដ្ឋ

- រាល់ការអនុញ្ញាតក្នុងមូលដ្ឋាន តំបន់ និងរដ្ឋទាំងអស់ សម្រាប់ បរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតទ្រង់ទ្រាយធំ ដែលត្រូវបានរួមបញ្ចូលទៅជា**ការអនុញ្ញាតរួមមួយ**ដែលចេញដោយ EFSB។
- រាល់ទីភ្នាក់ងារប្រចាំរដ្ឋ និងមូលដ្ឋានទាំងអស់ដែលនឹងមានតួនាទីផ្តល់ការអនុញ្ញាតផ្សេងទៀតអាច**ធ្វើអន្តរាគមន៍ និងចូលរួមដោយស្វ័យប្រវត្តិ**តាមរយៈការចេញសេចក្តីថ្លែងការណ៍អំពីលក្ខខណ្ឌអនុញ្ញាតដូចបានផ្តល់ការណែនាំ។
- រាល់គម្រោងទាំងអស់ត្រូវតែដាក់បញ្ចូនការវិភាគផលប៉ះពាល់សរុបដែលជាផ្នែកនៃការដាក់ពាក្យសុំទៅកាន់ EFSB។
- សេចក្តីសម្រេចលើការអនុញ្ញាតត្រូវតែចេញក្នុងរយៈពេល**តិចជាង 15 ខែ**ចាប់ពីការកំណត់ភាពពេញលេញនៃការដាក់ពាក្យសុំ។
- សេចក្តីសម្រេចរបស់ EFSB អាចដាក់បណ្តឹងឧទ្ធរណ៍ដោយផ្ទាល់ទៅតុលាការកំពូលដែលមានដែនសមត្ថកិច្ច។



- អនុវត្តចំពោះកន្លែងផលិតថាមពលទំហំ >25 MW កន្លែងផ្ទុកថាមពលទំហំ >100 MWh ហេដ្ឋារចនាសម្ព័ន្ធទាក់ទងនឹងទួរប៊ីនខ្យល់នៅឯនាយសមុទ្រ និងគម្រោងបញ្ជូនថាមពលថ្មីខ្នាតធំ

# ការអនុញ្ញាតក្នុងតំបន់រួម

- រដ្ឋាភិបាលក្នុងមូលដ្ឋាន (អាជ្ញាធរក្រុង និងស្ថាប័នការប្រចាំតំបន់ដូចជាស្ថាប័នការនៅ Cape Cod និង Martha's Vineyard ជាដើម) **រក្សាអំណាចផ្តល់ការអនុញ្ញាតទាំងអស់សម្រាប់គម្រោងដែលមិនស្ថិតក្រោមការពិនិត្យដោយ EFSB។**
- រដ្ឋាភិបាលក្នុងមូលដ្ឋាន**អាចបន្តដំណើរការអនុម័តដាច់ដោយឡែក**ក្នុងពេលដំណាលគ្នា (ឧទាហរណ៍ តំបន់ដីសើម ការកំណត់តំបន់ ជាដើម) ប៉ុន្តែត្រូវបានតម្រូវឱ្យ**ចេញការអនុញ្ញាតតែមួយ**ដែលរួមបញ្ចូលការអនុម័តជាលក្ខណៈបុគ្គលសម្រាប់ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត។
- សេចក្តីសម្រេចលើការអនុញ្ញាតត្រូវតែចេញ**ក្នុងរយៈពេល 12 ខែ**។
- រដ្ឋាភិបាលក្នុងមូលដ្ឋានអាចបញ្ជូនការពិនិត្យវាតម្លៃដើម្បីផ្តល់ការអនុញ្ញាតដោយផ្ទាល់ទៅកាន់ EFSB ប្រសិនបើពួកគេមិនមានធនធានគ្រប់គ្រាន់។
- ការដាក់ពាក្យសុំការអនុញ្ញាតក៏អាចត្រូវពិនិត្យវាយតម្លៃដោយ EFSB បន្ទាប់ពីសេចក្តីសម្រេចចុងក្រោយរបស់រដ្ឋាភិបាលក្នុងមូលដ្ឋាន ប្រសិនបើការពិនិត្យវាយតម្លៃត្រូវបានស្នើសុំដោយភាគីដែលអាចបង្ហាញថា ពួកគេទទួលរងផលប៉ះពាល់យ៉ាងខ្លាំង និងយ៉ាងជាក់លាក់ដោយការសម្រេចចិត្ត បន្ទាប់មកប្តឹងឧទ្ធរណ៍បន្ថែមទៀតដោយផ្ទាល់ទៅតុលាការកំពូលដែលមានដែនសមត្ថកិច្ច។
- ក្រសួង DOER ទទួលខុសត្រូវ**ក្នុងការបង្កើតពាក្យសុំការអនុញ្ញាតស្តង់ដាររបស់អាជ្ញាធរក្រុង និងបណ្តុំរួមនៃស្តង់ដាសុខភាព សុវត្ថិភាព និងបរិស្ថានកម្រិតមូលដ្ឋាន** ដែលត្រូវប្រើដោយអ្នកធ្វើការសម្រេចចិត្តក្នុងមូលដ្ឋាននៅពេលអនុញ្ញាតឱ្យមានហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត។



- អនុវត្តចំពោះគ្រឿងបរិក្ខារផលិតថាមពលទំហំ <25 MW គ្រឿងបរិក្ខារផ្ទុកថាមពលទំហំ <100 MWh និងគម្រោងបញ្ជូនចរន្ត និងចែកចាយថាមពលដែលមិនមែនក្នុងដែនសមត្ថកិច្ចរបស់ EFSB

# ការចូលរួមពីសហគមន៍កាន់តែមានអត្ថន័យ និងយុត្តិធម៌

- ការបង្កើតការិយាល័យយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថានជាផ្លូវការទៅតាមលក្ខន្តិកៈដែលមានអាណត្តិជាក់លាក់ ដើម្បីបង្កើតការណែនាំទាក់ទងនឹងកិច្ចព្រមព្រៀងអត្ថប្រយោជន៍សហគមន៍ និងការវិភាគផលប៉ះពាល់រួម។

- លក្ខខណ្ឌតម្រូវនៃការចូលរួមជាចាំបាច់របស់សហគមន៍ជាលើកដំបូង រួមបញ្ចូលទាំងការចងក្រងឯកសារអំពីកិច្ចខិតខំប្រឹងប្រែងដើម្បីចូលរួមជាមួយអង្គការក្នុងសហគមន៍ និងការបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតកិច្ចព្រមព្រៀងអត្ថប្រយោជន៍សហគមន៍។

- ផ្នែកការចូលរួមជាសាធារណៈថ្មីនៅនាយកដ្ឋាន DPU ដើម្បីជួយដល់សហគមន៍ និងអ្នកដាក់ពាក្យស្នើសុំគម្រោង ចំពោះសំណួរនានាអំពីការចូលរួម និងដំណើរការនៃនីតិវិធីរបស់នាយកដ្ឋាន DPU និង EFSB។

- ផ្នែកថ្មីខាងជ្រើសរើសទីតាំង និងផ្តល់ការអនុញ្ញាតនៅក្រសួង DOER ដើម្បីជួយដល់សំណួរនានាអំពីការចូលរួម និងដំណើរការក្នុងការផ្តល់ការអនុញ្ញាតក្នុងមូលដ្ឋានសម្រាប់សហគមន៍ និងអ្នកដាក់ពាក្យស្នើសុំគម្រោង។

- ជំនួយហិរញ្ញវត្ថុរបស់អន្តរការីមានសម្រាប់អង្គភាពដែលខ្វះខាតធនធាន ដែលចង់ចូលរួមក្នុងដំណើរការនីតិវិធីរបស់ EFSB ហើយត្រូវបានផ្តល់ឋានៈជាអន្តរការី។ អាជ្ញាធរក្រុងដែលមានប្រជាជនចំនួន 7,500 នាក់ ឬតិចជាងនេះមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុដោយស្វ័យប្រវត្តិ។

# កំណែទម្រង់បន្ថែម

- EEA តម្រូវឱ្យបង្កើតវិធីសាស្ត្រ និងការណែនាំអំពីភាពសមស្របនៃទីតាំង ដើម្បីជូនដំណឹងដល់ដំណើរការនៃការអនុញ្ញាតរបស់រដ្ឋ និងមូលដ្ឋានអំពីភាពសមស្របនៃទីតាំងសម្រាប់ការអភិវឌ្ឍថាមពលស្អាត និងជួយអ្នកអភិវឌ្ឍ ដើម្បីបញ្ចៀស កាត់បន្ថយ និងបន្ធូរបន្ថយផលប៉ះពាល់បរិស្ថាន។
- អាសនៈថ្មីចំនួនប្រាំនៅក្នុងក្រុមប្រឹក្សាភិបាល EFSB៖
  - ស្នងការរបស់នាយកដ្ឋានជលផល និងរុក្ខាប្រមាញ់
  - ស្នងការផ្នែកសុខភាពសាធារណៈ
  - អ្នកតំណាងនៃសមាគមអាជ្ញាធរក្រុងក្នុងរដ្ឋ Massachusetts
  - អ្នកតំណាងនៃសមាគមក្នុងរដ្ឋ Massachusetts របស់សមាគមរៀបចំផែនការប្រចាំតំបន់ និង
  - អ្នកតំណាងដែលមានជំនាញខាងយុត្តិធម៌លើផ្នែកបរិស្ថាន និង/ឬអធិបតេយ្យភាពជនជាតិរបស់ដើមភាគតិច។
- ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតនៅក្រោមយុត្តាធិការរបស់ EFSB ត្រូវបានលើកលែងចេញពីការពិនិត្យដោយច្បាប់ស្តីពីគោលនយោបាយបរិស្ថានក្នុងរដ្ឋ Massachusetts (MEPA)។
- អាជ្ញាធរមានសមត្ថកិច្ចក្នុងការកំណត់ទីតាំងនាយកដ្ឋាន DPU ពីដើមមក (ឧទាហរណ៍ ការអនុញ្ញាតឱ្យកំណត់តំបន់ទូទៅ និងសិទ្ធិយកដីមកប្រើសម្រាប់ការបញ្ជូនថាមពល និងបណ្តាញទុយយោ) ត្រូវបានផ្ទេរទៅកាន់ EFSB។

# តួនាទី និងទំនួលខុសត្រូវ

- មានចរន្តការងារចំនួនប្រាំដែលកើតចេញច្បាប់ ដែលកំពុងអនុវត្តដោយទីភ្នាក់ងារបីផ្សេងគ្នាគឺការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EEA) នាយកដ្ឋាននៃការចូលរួមជាសាធារណៈ (DPU) និងក្រសួងធនធានថាមពល (DOER)
- ភាគច្រើននៃចរន្តការងារទាំងនេះទាក់ទងគ្នាតាមរបៀបមួយចំនួន ប៉ុន្តែទីភ្នាក់ងារនីមួយៗបម្រើគោលបំណងដាច់ដោយឡែកពីគ្នា ហើយបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់ជាក់លាក់
- ទីភ្នាក់ងារទាំងបីមានការប្រាស្រ័យទាក់ទងយ៉ាងជិតស្និទ្ធជាមួយគ្នា
- ទីភ្នាក់ងាររដ្ឋផ្សេងទៀតដែលមានតួនាទីក្នុងការអនុញ្ញាតខាងថាមពលសំខាន់ៗក៏ទទួលបានការពិគ្រោះយោបល់ផងដែរ ខណៈដែលសំណើត្រូវបានបង្កើតឡើង

**ចរន្តការងារ**

| | | | | |
|---|---|---|---|---|
| **ការណែនាំអំពីភាពសមស្រប នៃទីតាំង** | **ផលប៉ះពាល់រួម និងការណែនាំ អំពីអត្ថប្រយោជន៍សហគមន៍** | **វិធាននៃការកំណត់ទីតាំង និងការអនុញ្ញាតសម្រាប់ អាជ្ញាធរក្រុង** | **វិធាននៃការជ្រើសរើសទីតាំង និងការអនុញ្ញាតរបស់ EFSB** | **ច្បាប់ស្តីពីជំនួយមូលនិធិ សម្រាប់អន្តរការីនៃនាយកដ្ឋាន DPU** |
| *ការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EEA)* | *ការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EEA)* | *DOER* | *EFSB* | *DPU* |

# ជំហានបន្ទាប់

- បទប្បញ្ញត្តិនេះត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី 1 ខែ មីនា ឆ្នាំ 2026។
  - ថវិកា FY25 បន្ថែមរបស់អភិបាលដែលបានដាក់នៅថ្ងៃទី2 ខែមេសាស្នើឱ្យពន្យារកាលកំណត់នេះរហូតដល់ថ្ងៃទី 1 ខែឧសភា ឆ្នាំ 2026។
- EEA, DPU និង EFSB បានកំណត់ពេលប្រជុំភាគីពាក់ព័ន្ធចំនួនបួនលើកសម្រាប់ខែមេសា និងខែឧសភា ហើយកំពុងបញ្ចេញពង្រាងសំណើលើប្រធានបទជាក់លាក់មុនកិច្ចប្រជុំទាំងនេះ។
- ពង្រាងបទប្បញ្ញត្តិនេះនឹងត្រូវបានចេញផ្សាយសម្រាប់មតិសាធារណៈ ប្រហែលនៅចុងរដូវក្តៅ/ដើមរដូវស្លឹកឈើជ្រុះ។
- ក្រសួង DOER និង DPU កំពុងរើសបុគ្គលិកថ្មី។
- ព័ត៌មានបន្ថែមអំពីដំណើរការអាចរកបាននៅលើគេហទំព័រៈ www.mass.gov/energypermitting
- អ្នកអាចបញ្ជូនសំណួរទៅអាសយដ្ឋានអ៊ីមែល energypermitting@mass.gov

# បេសកកម្មរបស់យើង

## បេសកកម្មរបស់ DOER គឺដើម្បីបង្កើតអនាគតប្រកបដោយថាមពលស្អាត មានតម្លៃសមរម្យ មានភាពធន់ និងគ្រប់គ្រាន់សម្រាប់មនុស្សគ្រប់រូបនៅក្នុង Commonwealth។

**យើងជានរណា៖** ក្នុងនាមជាការិយាល័យថាមពលរដ្ឋ DOER គឺជាទីភ្នាក់ងារគោលនយោបាយថាមពលជាមូលដ្ឋានសម្រាប់ Commonwealth។ DOER គាំទ្រដល់គោលដៅថាមពលស្អាតរបស់ Commonwealth ជាផ្នែកមួយនៃការឆ្លើយតបគ្រប់ជ្រុងជ្រោយទៅនឹងការគំរាមកំហែងពីការផ្លាស់ប្តូរអាកាសធាតុ។ DOER ផ្តោតលើការផ្លាស់ប្តូរការផ្គត់ផ្គង់ថាមពលរបស់យើងទៅការបំពុលបរិស្ថាន និងការចំណាយតិចជាងមុន ការកាត់បន្ថយ និងកែច្នៃតម្រូវការថាមពល នឹងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធថាមពលរបស់យើង។

**អ្វីដែលយើងធ្វើ៖** ដើម្បីបំពេញតាមគោលដៅរបស់យើង DOER បានតភ្ជាប់ និងសហការជាមួយភាគីពាក់ព័ន្ធក្នុងវិស័យថាមពលដើម្បីបង្កើតគោនយោបាយប្រកបដោយប្រសិទភាព។ DOER អនុវត្តគោលនយោបាយនេះតាមរយៈការធ្វើផែនការ បទប្បញ្ញត្តិ និងការផ្តល់មូលនិធិ។ DOER ផ្តល់ឧបករណ៍ដល់បុគ្គល អង្គការ និងសហគមន៍ដើម្បីគាំទ្រដល់គោលដៅថាមពលស្អាតរបស់ពួកគេ។ DOER បានប្តេជ្ញាចិត្តចំពោះតម្លាភាព នឹងការអប់រំ ដោយគាំទ្រការទទួលបានព័ត៌មាន និងចំណេះដឹងអំពីថាមពល។



**យើងគឺជាទីភ្នាក់ងារ**

របស់ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពល និងបរិស្ថាន (EEA)។

# ទំនួលខុសត្រូវក្នុងការអនុញ្ញាត និងការកំណត់ទីតាំងរោងចក្រថាមពលស្អាត

## ច្បាប់អាកាសធាតុឆ្នាំ 2024 នៅផ្នែកស្តីពីការកំណត់ទីតាំង និងការអនុញ្ញាតបានបង្រួបបង្រួមការពិនិត្យវាយតម្លៃ និងដំណើរការអនុម័តការអនុញ្ញាតនៅកម្រិតរដ្ឋ និងក្នុងតំបន់



គម្រោងខ្នាតធំ - ក្រុមប្រឹក្សាភិបាលជ្រើសរើសទីតាំងគ្រឿងបរិក្ខារថាមពល (EFSB)

- **លិខិតអនុញ្ញាតតែមួយរួមគ្នា**ពី ESFB ជំនួសឱ្យលិខិតអនុញ្ញាតពីរដ្ឋ តំបន់ និងកម្រិតមូលដ្ឋានជាច្រើន
- សេចក្តីសម្រេច**ក្នុងរយៈពេល 15 ខែ**



គម្រោងខ្នាតតូច - សាលាក្រុង

- **លិខិតអនុញ្ញាតតែមួយរួមគ្នាពីអង្គភាពសាលាក្រុង** ជំនួសឱ្យលិខិតអនុញ្ញាតកម្រិតមូលដ្ឋានជាច្រើន
- សេចក្តីសម្រេច**ក្នុងរយៈពេល 12 ខែ**

# តួនាទីរបស់ DOER

**ច្បាប់នេះបានបង្កើតតួនាទីថ្មី – និងផ្ទៃការងារថ្មី – សម្រាប់ក្រសួង DOER ដើម្បីគាំទ្រដំណើរការកំណត់ទីតាំងរោងចក្រថាមពលក្នុងតំបន់ និងការអនុញ្ញាតឱ្យមានហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតតូចៗ។**

នាយកដ្ឋានកំណត់ទីតាំងរោងចក្រថាមពល និងអនុញ្ញាតថាមពលស្អាតនឹងបង្កើតបទប្បញ្ញត្តិ និងផ្តល់ការគាំទ្របច្ចេកទេស និងជំនួយដល់ក្រុង អ្នកស្នើគម្រោង និងភាគីពាក់ព័ន្ធផ្សេងទៀត។

នៅក្នុងបទប្បញ្ញត្តិរបស់ DOER តម្រូវឱ្យបង្កើត៖

- ស្តង់ដាសុខភាពសាធារណៈ សុវត្ថិភាព និងបរិស្ថាន
- *ការដាក់ពាក្យស្នើសុំស្តង់ដាទូទៅ*
- លក្ខខណ្ឌតម្រូវនៃការដាក់ឯកសារជាមុន
- ស្តង់ដាសម្រាប់ការអនុវត្តការណែនាំអំពីភាពសមស្របនៃទីតាំង
- លិខិតអនុញ្ញាតរួម
- ការណែនាំសម្រាប់នីតិវិធី/ ពេលវេលាកំណត់
- គូភាគីទទួលខុសត្រូវចំពោះការអនុវត្ត
- ដំណើរការបង់ថ្លៃសេវាក្រុងសម្រាប់សំណងលើការកាត់បន្ថយផលប៉ះពាល់បរិស្ថាន (មិនតម្រូវទេ)
- វិធាន និងលក្ខខណ្ឌតម្រូវទូទៅ


MASSACHUSETTS DEPARTMENT OF ENERGY RESOURCES

# បន្ទាត់ពេលវេលាឆ្នាំ 2025

ការកំណត់ទីតាំង និងការអនុញ្ញាតរបស់ DOER នៅឆ្នាំ 2025 នឹងមានបីដំណាក់កាលៈ

01

**ការកំណត់ផ្នែកការងារថ្មី**

**រដូវរងា-រដូវក្តៅៈ**
ការជ្រើសរើសបុគ្គលិកថ្មី និង ការណែនាំអំពីទំនួលខុសត្រូវ

02

**ការចូលរួមពីភាគីពាក់ព័ន្ធ**

**និទាឃរដូវ -រដូវក្តៅៈ**
ខាងក្នុង និងខាងក្រៅ កំណត់គោលដៅឱ្យបានទូលំទូលាយជាងមុន

03

**សេចក្តីព្រាង បទប្បញ្ញត្តិ**

**ចុងរដូវក្តៅ/រដូវស្លឹកឈើជ្រុះៈ**
បោះពុម្ពផ្សាយសេចក្តីព្រាងបទប្បញ្ញត្តិ
*(បទប្បញ្ញត្តិចុងក្រោយដល់កាលកំណត់ត្រឹមថ្ងៃទី 1 ខែ មីនា ឆ្នាំ 2026)*

# ទាក់ទងមកយើងខ្ញុំ

100 Cambridge St. - 9th Floor - Boston, MA 02114

doer.siting.permitting@mass.gov

(617) 626-7300

x.com/massdoer

bsky.app/profile/massdoer.bsky.social

www.mass.gov/orgs/massachusetts-department-of-energy-resources

## យើងទន្ទឹងរង់ចាំទទួលបានព័ត៌មានពីអ្នក។



# តើក្រុមប្រឹក្សាភិបាលកំណត់ទីតាំងផលិតថាមពលជាអ្វី?

- ក្រុមប្រឹក្សាឯករាជ្យមួយ ត្រូវបានបង្កើតឡើងប្រហែល 50 ឆ្នាំមុន (អតីតក្រុមប្រឹក្សានៃការកំណត់ទីតាំងផលិតថាមពល (EFSC))
- មានសមាជិកចំនួនប្រាំបួននាក់៖ សមាជិកដែលមានមុខដំណែងចំនួនប្រាំមួយនាក់ និងសមាជិកសាធារណៈចំនួនបីនាក់ ដែលដឹកនាំដោយរដ្ឋលេខាធិការក្រសួងថាមពល និងបរិស្ថាន។
  - យុត្តាធិការរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងមានចំពោះបរិក្ខារផលិតថាមពលធំៗដែលកំណត់ដោយលក្ខន្តិកៈ៖
    - បរិក្ខារផលិតថាមពលស្មើ ឬច្រើនជាង 100 MW និងរចនាសម្ព័ន្ធបន្ថែម (កម្រិតកំណត់នេះត្រូវបានកាត់បន្ថយដល់ 25 MW នៅក្នុងច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024)
    - បណ្តាញបញ្ជូនចរន្តអគ្គិសនី
      - សម្រាប់ច្រករបៀងថ្មី៖ ≥ 69 kV **និង** ≥ប្រវែង 1 ម៉ាយល៍
      - ច្រករបៀងដែលមានស្រាប់៖ ≥ 115 kV **និង** ≥ប្រវែង 10 ម៉ាយល៍ លើកលែងតែការបញ្ជូនឡើងវិញ ឬការសាងសង់ឡើងវិញក្នុងកម្រិតតង់ស្យុងដូចគ្នា
    - បណ្តាញទុយយោបង្ហូរឧស្ម័ននៅក្នុងរដ្ឋលើសពី 100 psig **និង**ប្រវែងលើសមួយម៉ាយល៍ លើកលែងតែការសាងសង់ឡើងវិញ ឬការតម្លើងទុយយោបង្ហូរឧស្ម័នដែលមានស្រាប់
    - កន្លែងផ្ទុកឧស្ម័ន (ឧស្ម័នធម្មជាតិរាវ (LNG) ឬឧស្ម័នធម្មជាតិដែលបានបង្ហាប់ (CNG)) លើសពី 25,000 ហ្គាឡុង
    - កន្លែងផ្ទុក/ទុយយោបង្ហូរប្រេងដែលមានប្រវែងជាង 1 ម៉ាយល៍ ធុងផ្ទុកថ្មីលើស 500,000 បារ៉ែល
- ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងរៀបចំដំណើរការនីតិវិធីវិនិច្ឆ័យ ចេញសេចក្តីសម្រេចលើការដាក់ពាក្យដើម្បីសាងសង់ និងបញ្ជាក់ពីផលប៉ះពាល់បរិស្ថាន និងផលប្រយោជន៍សាធារណៈ សម្រាប់ទីតាំងនៅក្រោមយុត្តាធិការ ក៏ដូចជាការអនុវត្តសិទ្ធិអំណាចលើការលើកលែងពីការកំណត់តំបន់។
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងអាចត្រូវបានដាក់បណ្តឹងឧទ្ធរណ៍ដោយផ្ទាល់ទៅតុលាការកំពូលដែលមានដែនសមត្ថកិច្ច។
- ផ្នែកកំណត់ទីតាំងរបស់ DPU បម្រើការងារជាបុគ្គលិករបស់ស្ថងការ EFSB និង DPU

# បទប្បញ្ញត្តិស្តីពីការកំណត់ទីតាំង និងការអនុញ្ញាតសំខាន់ៗនៃច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024

- ពង្រីកក្រុមប្រឹក្សាកំណត់ទីតាំងពីសមាជិកចំនួនប្រាំបួនទៅដប់មួយនាក់ ដោយបង្កើតអាណត្តិថ្មី វិសាលភាពនៃការពិនិត្យវាយតម្លៃ និងលទ្ធផលដែលតម្រូវឱ្យមាន។
- បង្កើតប្រភេទហេដ្ឋារចនាសម្ព័ន្ធថ្មី៖ បរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត (“CEIF”)។
- បង្កើតកម្មវិធីអនុញ្ញាតរួមទាំងពីរ។
  - ការអនុញ្ញាតរួមគឺជាការអនុញ្ញាតមួយដែលរួមបញ្ចូលទាំងការអនុញ្ញាតរបស់រដ្ឋ តំបន់ និងមូលដ្ឋានទាំងអស់ ដែលនឹងត្រូវការដើម្បីសាងសង់ និងដំណើរការហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត (CEIF)។ និយមន័យនេះមិនរាប់បញ្ចូលការអនុញ្ញាតសហព័ន្ធមួយចំនួននោះទេ។
    - CEIF ខ្នាតធំ - ការអនុញ្ញាតរួមដែលត្រូវផ្តល់ដោយក្រុមប្រឹក្សាកំណត់ទីតាំង។
    - CEIF ខ្នាតតូច - ការអនុញ្ញាតរួមក្នុងតំបន់ដែលត្រូវផ្តល់ដោយអាជ្ញាធរក្រុង។
- ផ្តល់កាលបរិច្ឆេទកំណត់សម្រាប់ការពិនិត្យ CEIF ឡើងវិញ និងការអនុម័តលើការសាងសង់ ប្រសិនបើមិនបានបំពេញតាមកាលបរិច្ឆេទកំណត់ទេនោះ។
- បង្កើតលក្ខខណ្ឌតម្រូវថ្មីៗសម្រាប់អ្នកដាក់ពាក្យស្នើសុំ CEIF រួមមាន៖
  - ការប្រឹក្សាយោបល់ និងការចូលរួមមុនការដាក់ឯកសារស្នើសុំ។
  - ការវាយតម្លៃផលប៉ះពាល់សរុប (CIA) (តម្រូវឱ្យមានផងដែរនូវការវាយតម្លៃដែលមិនមែនជា CEIF)។
- ប្តូរយុត្តាធិការកំណត់ទីតាំងរបស់ក្រសួងសេវាសាធារណៈមួយចំនួនទៅជាការទទួលខុសត្រូវកំណត់ទីតាំងរួមរបស់ក្រុមប្រឹក្សាកំណត់ទីតាំង។

# លក្ខខណ្ឌតម្រូវថ្មីៗសម្រាប់ក្រុមប្រឹក្សាកំណត់ទីតាំង

- កែសម្រួលសមាជិកភាពនៃក្រុមប្រឹក្សាកំណត់ទីតាំង។ ជំពូកនៃច្បាប់ទូទៅ 164, § 69H។
  - បន្ថែមមុខតំណែងថ្មីចំនួនពីរ – ក្រសួងជលផល និងរុក្ខាប្រមាញ់ និងក្រសួងសុខភាពសាធារណៈ (និងកាត់បន្ថយក្រសួងសាធារណៈមកត្រឹមមួយអាសនៈ)។
  - បង្កើនចំនួនអាសនៈសម្រាប់សមាជិកសាធារណៈពីបីទៅបួនអាសនៈ៖ រដ្ឋ Mass។ សមាគមទីភ្នាក់ងាររៀបចំផែនការក្នុងតំបន់ រដ្ឋ Mass សមាគមក្រុងនៃរដ្ឋ Mass ផ្នែកយុត្តិធម៌បរិស្ថាន/អធិបតេយ្យភាពជនជាតិដើមភាគតិច និងកម្លាំងពលកម្ម (និងលុបចោលសមាជិកសាធារណៈដែលតំណាងឱ្យថាមពល និងបរិស្ថាន)។
- ពង្រីកយុត្តាធិការរបស់ក្រុមប្រឹក្សាកំណត់ទីតាំង។ ឧទាហរណ៍ បន្ថែមយុត្តាធិការលើប្រព័ន្ធផ្ទុកថាមពលថ្ម។
- បង្កើតប្រភេទថ្មី និងច្បាប់វិធានថ្មីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត (CEIF)។
- បង្កើតដំណើរការថ្មីសម្រាប់ក្រុមប្រឹក្សាកំណត់ទីតាំងដើម្បីចេញលិខិតអនុញ្ញាតរួម។

# លក្ខខណ្ឌតម្រូវថ្មីៗសម្រាប់ក្រុមប្រឹក្សាកំណត់ទីតាំង (ត)

- កំណត់អាណត្តិផ្លូវច្បាប់ថ្មី និងវិសាលភាពនៃការពិនិត្យវាយតម្លៃសម្រាប់ក្រុមប្រឹក្សាកំណត់ទីតាំង។
    - ក្រុមប្រឹក្សាកំណត់ទីតាំងកំពុងតែកំណត់ថា តើគម្រោងមួយនឹងផ្តល់នូវការផ្គត់ផ្គង់ថាមពលដែលអាចជឿជាក់បានដោយមានផលប៉ះពាល់ដល់បរិស្ថានជាអប្បបរមា និងមានតម្លៃតិចបំផុតដែរឬទេ។
    - ស្ថិតក្រោមច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 នៅពេលពិនិត្យមើលគម្រោងដែលបានស្នើឡើង ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងត្រូវតែពិចារណាចំណុចផ្សេងរួមមានទាំង បន្ទុកជារួមលើសហគមន៍ដែលជាម្ចាស់ផ្ទះ ផលប៉ះពាល់សុខភាពសាធារណៈ និងផលប៉ះពាល់លើការប្រែប្រួលអាកាសធាតុ។ ច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 ក៏រួមមានបញ្ញើលទ្ធផល ដែលក្រុមប្រឹក្សាកំណត់ទីតាំងត្រូវធ្វើសេចក្តីសម្រេចរបស់ខ្លួនលើគម្រោងដែលបានស្នើឡើងផងដែរ។
- បន្ថែមកាលបរិច្ឆេទកំណត់តាមច្បាប់សម្រាប់ការពិនិត្យវាយតម្លៃរបស់ក្រុមប្រឹក្សាកំណត់ទីតាំងទៅលើ CEIF ដែលបានស្នើឡើង។
    - ប្រសិនបើក្រុមប្រឹក្សាកំណត់ទីតាំងមិនចេញសេចក្តីសម្រេចត្រឹមថ្ងៃកំណត់ដែលបានតម្រូវ (មិនលើសពីរយៈពេល 15 ខែ) ទេ នោះគម្រោងនឹងត្រូវបានអនុម័តលើការសាងសង់ ហើយទទួលបានការអនុញ្ញាតរួមដោយមានលក្ខខណ្ឌស្តង់ដា។
- លក្ខខណ្ឌតម្រូវបន្ថែម
    - ការបង្កើតផ្ទាំងគ្រប់គ្រង
    - ក្រុមប្រឹក្សាកំណត់ទីតាំងត្រូវជួបប្រជុំនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាកំណត់ទីតាំងជាសាធារណៈបែបហាយប្រ៊ីដ
    - ការដាក់សំណើសុំស្តង់ដាធម្មតា

# បទប្បញ្ញត្តិនៃច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 សម្រាប់ “ការដាក់សំណើសុំស្តង់ដាធម្មតា”

- “ពាក្យសុំស្តង់ដាធម្មតា” គឺជាពាក្យសុំដែលត្រូវបានប្រើនៅក្នុងច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 សម្រាប់ការដាក់ពាក្យដោយអ្នកស្នើសុំដែលកំពុងស្វែងរក “ការអនុញ្ញាតរួម” ពី EFSB  និងរដ្ឋាភិបាលមូលដ្ឋាន។
- ចាត់ទំនួលខុសត្រូវដល់ EFSB និង DOER សម្រាប់ការបង្កើតប្រភេទផ្សេងៗនៃសំណើសុំ CEIF។
- ផ្តល់ការពិពណ៌នាកម្រិតខ្ពស់ក្នុងខ្លឹមសារការដាក់ពាក្យសម្រាប់ប្រភេទផ្សេងៗនៃ CEIF។
- <u>មិន</u>ត្រូវកំណត់ទម្រង់ និងព័ត៌មានលម្អិតនៃការដាក់ពាក្យសុំនោះឡើយ។ ភារកិច្ចក្នុងបទប្បញ្ញត្តិនេះត្រូវបានទុកឱ្យ EFSB ហើយសំណើរបស់បុគ្គលិក EFSB សម្រាប់ការដាក់សំណើសុំ EFSB គឺជាប្រធានបទនៃសម័យប្រជុំថ្ងៃនេះ។

# ការដាក់ពាក្យមក EFSB និង DOER ដើម្បីស្នើសុំបរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត

- **តួនាទីរបស់** EFSB៖ បង្កើត "ពាក្យសុំស្តង់ដាទូទៅ" មួយសម្រាប់៖ (1) ការអនុញ្ញាតរួមរបស់រដ្ឋ និងមូលដ្ឋាន និង (2) ការអនុញ្ញាតរួមរបស់រដ្ឋ
  - បរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតទ្រង់ទ្រាយធំៗ (“LCEIF”) (§69T) [ការអនុញ្ញាតរួមថ្នាក់រដ្ឋ + តំបន់]។
  - បរិក្ខារបញ្ជូន និងចែកចាយថាមពលស្អាតទ្រង់ទ្រាយតូច (“SCT&D”) (§69U) [ការអនុញ្ញាតរួមថ្នាក់រដ្ឋ + តំបន់]។
  - ការបង្កើតថាមពលស្អាតទ្រង់ទ្រាយតូច (“SCEG”) និងបរិក្ខារផ្ទុកថាមពលស្អាតខ្នាតតូច (“SCES”) (§69V) [ការអនុញ្ញាតរួមរបស់រដ្ឋ]។
- **តួនាទីរបស់ DOER**៖ បង្កើត “ពាក្យស្នើសុំស្តង់ដាជម្មតា” សម្រាប់ការអនុញ្ញាតរួមក្នុងមូលដ្ឋានសម្រាប់បរិក្ខារហេដ្ឋារចនាសម្ព័ន្ធផលិតថាមពលស្អាតទ្រង់ទ្រាយតូច (“SCEIF”)៖
  - បរិក្ខារបង្កើត ផ្ទុក បញ្ជូននិងចែកចាយ (T&D) ថាមពលស្អាតទ្រង់ទ្រាយតូច។

# បរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត

| **ប្រភេទ/ការពិពណ៌នាអំពីបរិក្ខារ** | **សមត្ថភាព/ទំហំ** | **សិទ្ធអំណាចនៃការអនុញ្ញាត** |
|---|---|---|
| **ការបង្កើតថាមពល** – ពន្លឺព្រះអាទិត្យ ខ្យល់ ដំណើរការរំលាយជាតិសរីរាង្គដោយគ្មានអុកស៊ីសែន | ≥ 25 MW (**ធំ**) | EFSB – ដំណើរការនៃការអនុញ្ញាតរួមរបស់រដ្ឋ និងក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាម § 69T |
| | <25 MW (**តូច**) | ក្នុងមូលដ្ឋាន - ដំណើរការនៃការអនុញ្ញាតរួមក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាមជំពូក 25A, § 21 [1]<br>EFSB – ការអនុញ្ញាតជារួមរបស់រដ្ឋស្របតាមច្បាប់ § 69V (EFSB ដែលអ្នកអភិវឌ្ឍជ្រើសចូលរួម) បើមិនដូច្នេះទេ ត្រូវមានការអនុញ្ញាតរបស់រដ្ឋនីមួយៗ |
| **ប្រព័ន្ធផ្ទុកថាមពល** | ≥100 MWh (**ធំ**) | EFSB – ការអនុញ្ញាតជារួមរបស់រដ្ឋ និងក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាមច្បាប់ § 69T |
| | <100 MWh (**តូច**) | ក្នុងមូលដ្ឋាន - ដំណើរការនៃការអនុញ្ញាតរួមក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាមជំពូក 25A, § 21 [1]<br>EFSB – ការអនុញ្ញាតរួមរបស់រដ្ឋស្របតាមច្បាប់ § 69V (EFSB ដែលអ្នកអភិវឌ្ឍជ្រើសរើសចូលរួម) មិនដូច្នោះទេ ត្រូវមានការអនុញ្ញាតរបស់រដ្ឋនីមួយៗផ្សេងពីគ្នា |
| **ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនថាមពល** (និងបរិក្ខារជំនួយ) - **ខ្នាតធំ**<br>- ≥69 kV និង ≥ 1 ម៉ាយល៍ (ច្រករបៀងថ្មី)<br>- ≥115 kV និង ≥10 ម៉ាយល៍ (ច្រករបៀងដែលមានស្រាប់) (លើកលែងតែការបញ្ជូនឡើងវិញក្នុងតង់ស្យុងដូចគ្នា)<br>- ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនថាមពលថ្មី (រួមទាំងស្ថានីយរង/រចនាសម្ព័ន្ធ) ដែលតម្រូវឱ្យមានការលើកលែងពីការកំណត់តំបន់<br>- បរិក្ខាដែលត្រូវការដើម្បីភ្ជាប់នឹងទួរប៊ីនខ្យល់នៅឯនាយសមុទ្រទៅបណ្តាញចែកចាយអគ្គិសនី → | | EFSB – ដំណើរការនៃការអនុញ្ញាតរួមរបស់រដ្ឋ និងក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាម § 69T<br><br>ការលើកលែងពីការកំណត់តំបន់របស់ EFSB ក៏ត្រូវបានទាមទារផងដែរ |
| **ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនថាមពល** (និងបរិក្ខារជំនួយ) - **ខ្នាតតូច**<br>- <1 ម៉ាយល៍ (ច្រករបៀងថ្មី)<br>- <10 ម៉ាយល៍ (ច្រករបៀងដែលមានស្រាប់)<br>- គម្រោងកម្រិតចែកចាយដែលបំពេញតាមដែនកម្រិតកំណត់នៃទំហំដែលនឹងត្រូវកំណត់ពេលក្រោយដោយ DOER<br>- ការបញ្ជូនថាមពលបន្ត/ការសាងសង់ឡើងវិញក្នុងកម្រិតតង់ស្យុងដូចគ្នា<br>- ស្ថានីយរង/ការដំឡើងកម្រិតដែលមិនតម្រូវឱ្យមានការលើកលែងការកំណត់តំបន់ | | ក្នុងមូលដ្ឋាន - ដំណើរការនៃការអនុញ្ញាតរួមក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាមជំពូកទី 25A, § 21<br><br>- **ឬ** -<br><br>EFSB – ដំណើរការនៃការអនុញ្ញាតរួមរបស់រដ្ឋ និងក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាមច្បាប់ § 69U (EFSB ដែលអ្នកអភិវឌ្ឍជ្រើសរើសចូលរួម) |

1. ដំណើរការដាក់ឯកសារជាមុននឹងធ្វើឡើងជាលើកដំបូងក្រោមគោលការណ៍ណែនាំអំពីការអនុញ្ញាតរួមក្នុងមូលដ្ឋានរបស់ DOER ហើយនឹងមិនត្រូវស្ថិតក្រោមដំណើរការដាក់ឯកសារជាមុនរបស់ EFSB នោះទេ។ រដ្ឋាភិបាលក្នុងមូលដ្ឋានអាចផ្ទេរពាក្យសុំការអនុញ្ញាតរួមក្នុងតំបន់ទៅនាយករបស់ EFSB ប្រសិនបើធនធាន និងចំនួនបុគ្គលិកមិនអនុញ្ញាតឱ្យមានការត្រួតពិនិត្យក្នុងមូលដ្ឋានស្របតាមច្បាប់ § 69W ទេនោះ។ សំណើសុំសម្រាប់ការវិនិច្ឆ័យពីសេចក្តីសម្រេចការអនុញ្ញាតរួមក្នុងមូលដ្ឋានថ្មីក៏អាចត្រូវបានដាក់ជូនទៅនាយក EFSB ស្របតាមច្បាប់ § 69W ហើយនឹងមិនតម្រូវឱ្យមានដំណើរការដាក់ឯកសារជាមុនបន្ថែមឡើយ។

ពណ៌គន្លឹះ៖ ទំនួលខុសត្រូវនៃសំណើសុំរបស់ EFSB ទំនួលខុសត្រូវរបស់ DOER ដើម្បីបង្កើតសំណើសុំ

# បទប្បញ្ញត្តិនៃច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 សម្រាប់សំណើសុំហេដ្ឋារចនាសម្ព័ន្ធផលិតផលថាមពលស្អាតរបស់ EFSB

| ធាតុនៃការដាក់សំណើសុំដែលបានបញ្ជាក់ | LCT&D (ឬ SCT&D) | LCES ឬ LCEG (ឬ SCES/SCEG) |
|---|---|---|
| ការពិពណ៌នាអំពីទីតាំងបរិក្ខារ និងតំបន់ជុំវិញ | ✓ | ✓ |
| ការវិភាគលើតម្រូវការ និងអត្ថប្រយោជន៍ថាមពល | ✓ | មានតែអត្ថប្រយោជន៍ថាមពលប៉ុណ្ណោះ |
| ការពិពណ៌នាអំពីជម្រើសជំនួសសម្រាប់បរិក្ខារ រួមទាំងការកំណត់ទីតាំង និងគម្រោងជំនួស | ✓ | មានតែជម្រើសនៃការកំណត់ទីតាំងណុះណោះ |
| ការពិពណ៌នាអំពីផលប៉ះពាល់បរិស្ថានពីបរិក្ខារ រួមទាំងបន្ទុក និងអត្ថប្រយោជន៍ | ✓ | ✓ |
| ថ្លៃចំណាយរបស់គម្រោង | ✓ | |
| ភស្តុតាងដែលថា ការពិគ្រោះយោបល់មុនពេលដាក់ឯកសារជាមុន និងការតម្រូវឱ្យមានការចូលរួមរបស់សហគមន៍ទាំងអស់ត្រូវបានបំពេញតាម | ✓ | ✓ |
| ការវិភាគផលប៉ះពាល់រួម | ✓ | ✓ |

# គំនូសតាងជំហាននីតិវិធីរបស់ EFSB

## ដំណើរការរយៈពេល 15 ខែរបស់ EFSB

➤ = ចន្លោះពេលពាក្យសុំ

*អាចអនុវត្តបានចំពោះបរិក្ខារហេដ្ឋារចនាសម្ព័ន្ធផលិតថាមពលស្អាតទ្រង់ទ្រាយធំ (ឧទាហរណ៍)៖*

- *បណ្តាញខ្សែបញ្ជូនថ្មី (≥69 kV) នៅក្នុងច្រករបៀងថ្មី (≥1 ម៉ាយល៍)*
- *បណ្តាញខ្សែបញ្ជូនថ្មី (≥115 kV) នៅក្នុងច្រករបៀងដែលមានស្រាប់ (≥10 ម៉ាយល៍)*
- *ស្ថានីយ៍រងដែលតម្រូវឱ្យមានការលើកលែងពីបទបញ្ញត្តិកំណត់តំបន់ក្នុងមូលដ្ឋាន*
- *បណ្តាញខ្សែតភ្ជាប់សម្រាប់បរិក្ខារទួរប៊ីនខ្យល់នៅឯនាយសមុទ្រ*
- *បរិក្ខារផ្ទុកថាមពលទ្រង់ទ្រាយធំ (≥100 MWh)*
- *បរិក្ខារផលិតថាមពលស្អាតទ្រង់ទ្រាយធំ (≥25 MW)*

## ដំណើរការរយៈពេល 12 ខែរបស់ EFSB

*អាចអនុវត្តបានចំពោះបរិក្ខារហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយថាមពលស្អាតទ្រង់ទ្រាយតូច (ឧទាហរណ៍)៖*

- *គម្រោងជួសជុល និងសាងសង់ឡើងវិញនូវបណ្តាញខ្សែបញ្ជូន*
- *បណ្តាញខ្សែបញ្ជូនថ្មី/ដែលបានផ្លាស់ប្តូរសំខាន់ៗនៅក្នុងច្រករបៀងដែលមានស្រាប់ (<10 ម៉ាយល៍)*
- *បណ្តាញខ្សែបញ្ជូនដែលបានបញ្ជូនថ្មី/សំខាន់ៗនៅក្នុងច្រករបៀងថ្មី (<1 ម៉ាយល៍)*
- *ស្ថានីយ៍រងដែលមិនតម្រូវឱ្យមានការលើកលែងពីបទបញ្ញត្តិកំណត់តំបន់ក្នុងមូលដ្ឋាន*
- *គម្រោងកម្រិតចែកចាយដាក់លាក់ (កម្រិតដែលត្រូវកំណត់ដោយ DOER)*

| ជំហាននីតិវិធី/ខែ (M) |
|---|
| លក្ខខណ្ឌតម្រូវនៃការចូលរួមក្នុងការដាក់ឯកសារជាមុន ➤ |
| ការដាក់ពាក្យស្នើសុំគម្រោង និងការកំណត់ភាពពេញលេញ (ក្នុងរយៈពេល 1 ខែពីការដាក់ពាក្យសុំ) ➤ |
| សេចក្តីជូនដំណឹងជាសាធារណៈអំពីគម្រោង និងសវនាការមតិសាធារណៈ: (ក្នុងរយៈពេល 1 ខែពីការកំណត់ភាពពេញលេញ) |
| វិធានអន្តរាគមន៍ និងការផ្តល់ជំនួយ |
| សន្និសីទនីតិវិធីបឋម និងលំដាប់លំដោយនៃនីតិវិធី |
| សេចក្តីថ្លែងការណ៍អំពីលក្ខខណ្ឌអនុញ្ញាតដែលបានការណែនាំ |
| ការវិនិច្ឆ័យ និងសវនាការផ្តល់ភស្តុតាងរបស់ EFSB (រួមទាំងលទ្ធផលរកឃើញ និងការសង្ខេបជាលាយលក្ខណ៍អក្សរ) |
| សេចក្តីសម្រេច និងមតិយោបល់មិនច្បាស់លាស់របស់ EFSB (រួមទាំងសេចក្តីព្រាង និងការពិនិត្យឡើងវិញរបស់បុគ្គលិក) |
| កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលដើម្បីបោះឆ្នោតលើសេចក្តីសម្រេចចុងក្រោយ |




*EFSB – ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល*

# គោលបំណងសំខាន់ៗសម្រាប់ការដាក់សំណើសុំ EFSB

- ការដាក់សំណើសុំត្រូវតែមាន ឬឆ្លុះបញ្ចាំង៖
  - ព័ត៌មានគ្រប់គ្រាន់សម្រាប់ការកំណត់ភាពពេញលេញ
  - ពន្យល់រាល់ស្តង់ដា និងការណែនាំដែលអាចអនុវត្តបាន ដូចជា៖
    - លក្ខណៈវិនិច្ឆ័យ/ការណែនាំអំពីភាពសមស្របនៃទីតាំង
    - ការវិភាគផលប៉ះពាល់រួម
    - "សុខភាព សុវត្ថិភាព បរិស្ថាន និងស្តង់ដាកម្រិតមូលដ្ឋានផ្សេងទៀត" ដែលបង្កើតឡើងដោយក្រុម EFSB
- យោបល់របស់បុគ្គលិកសម្រាប់ "ឧត្តមានុវត្តន៍" នៃការដាក់ពាក្យសុំ
  - ទម្រង់ឯកសារស្តង់ដា និងការរៀបចំសម្រាប់ភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន
  - រួមបញ្ចូលព័ត៌មានសង្ខេបជាភាសាសាមញ្ញអំពីគម្រោង
  - រួមបញ្ចូលឯកសារគាំទ្រដើម្បីជៀសវាងការពន្យាពេលក្នុងការកំណត់ភាពពេញលេញ
  - រួមបញ្ចូលការដាក់បញ្ជូនវីដេអូខ្លីៗនៃទិដ្ឋភាពទូទៅនៃគម្រោង ជាពិសេសសម្រាប់គម្រោងធំៗ
  - សូមប្រើប្រាស់បច្ចេកវិទ្យាដែលមានប្រយោជន៍ (OCR តំណភ្ជាប់ទិន្នន័យ តារាងមាតិកា (TOC) ដែលមានតំណភ្ជាប់ និងនិយមន័យ)
  - ជាមួយនឹងការបញ្ចប់នៃច្បាប់ MEPA ក្នុងរដ្ឋ Massachusetts សម្រាប់ CEIF ភាគច្រើនស្របតាមច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 ចូរពិចារណាលើការបន្ថែមចំណុចព័ត៌មានដែលមានប្រយោជន៍ និងមានលក្ខណៈពិសេស ដែលដំណើរការច្បាប់ MEPA បានបំភ្លឺ

# ដំណើរការបង្កើតការដាក់ពាក្យសុំដោយបុគ្គលិក

- ការស្រាវជ្រាវលើពាក្យសុំតាមទីភ្នាក់ងារកំណត់ទីតាំង/អនុញ្ញាតនៅក្នុងរដ្ឋផ្សេងទៀត ជាពិសេសភ្នាក់ងារ ដែលមានកម្មវិធីអនុញ្ញាតរួម៖ NY, OR, WI, MI, RI, NH, CA។
- កំណត់អត្តសញ្ញាណការអនុញ្ញាតរបស់រដ្ឋ តំបន់ និងមូលដ្ឋានដែលជាធម្មតាត្រូវបានចេញសម្រាប់បរិក្ខារថាមពលនៅក្នុងរដ្ឋ Massachusetts ដោយប្រើឆ្នាំនៃករណីរបស់ EFSB និងឯកសារច្បាប់ MEPA។
- ការពិគ្រោះយោបល់ក្រៅផ្លូវការជាមួយមិត្តរួមការងារនៃទីភ្នាក់ងារអនុញ្ញាតក្នុងរដ្ឋ Massachusetts និងក្នុងតំបន់ និងមន្ត្រីនៅក្នុងរដ្ឋផ្សេងទៀត ស្វែងរកមតិយោបល់ពីភាគីពាក់ព័ន្ធបន្ថែម (រួមទាំងកម្រងសំណួរនាពេលអនាគតដែលអាចមាន)។
- បុគ្គលិកបានចំណាយពេលបំផុសគំនិត និងជួបជាមួយបុគ្គលិកទីភ្នាក់ងារផ្សេងទៀត។

# ការរួមបញ្ចូលគ្នានៃការដាក់ពាក្យស្នើសុំដែលមានស្រាប់ធៀប និងការដាក់ពាក្យស្នើសុំដែលបង្កើតតាមគោលបំណង

| ការពិចារណា/គុណលក្ខណៈ | ការរួមបញ្ចូលគ្នានៃការដាក់ពាក្យសុំដែលមានស្រាប់ | ការដាក់ពាក្យស្នើសុំដែលបង្កើតតាមគោលបំណង |
|---|---|---|
| ការពណ៌នា | នឹងរួមបញ្ចូលៈ (1) “ផ្នែកវិសាលភាពទូលំទូលាយ” ដូចជាការដាក់ពាក្យរបស់ EFSB នៅថ្ងៃនេះ និង (2) ផ្នែក “លក្ខខណ្ឌតម្រូវផ្សេងទៀតទាំងអស់” រួមទាំងការដាក់ពាក្យសុំការអនុញ្ញាត និងការដាក់ពាក្យដែលនឹងត្រូវបានទាមទារដោយទីភ្នាក់ងាររដ្ឋ តំបន់ និងមូលដ្ឋាន។ | ការតម្រូវឱ្យមានសំណុំឯកសារតែមួយ រួមបញ្ចូលគ្នាយ៉ាងទូលំទូលាយ ដែលនឹងជៀសវាងលក្ខខណ្ឌតម្រូវឱ្យដាក់ពាក្យសុំការអនុញ្ញាតម្តងមួយៗ បើមិនតម្រូវដូច្នេះទេនោះ |
| រដ្ឋដែលប្រើវិធីសាស្ត្រនេះ | RI, NH, OR (ដោយផ្នែក) | NY, WI, MI (ចំណាំៈ ការមនុម័តក្នុងការកំណត់ទីតាំងរបស់ WI និង MI មានសមត្ថភាពមានកម្រិតក្នុងការចេញការអនុញ្ញាតពីរដ្ឋ និងមូលដ្ឋានផ្សេងទៀត) |
| ការជៀសវាងព័ត៌មានស្ទួន/បទប្បញ្ញត្តិដែលផ្ទុយគ្នា | ផ្តល់ការណែនាំដល់អ្នកដាក់ពាក្យសុំឱ្យពិនិត្យព័ត៌មានឆ្លងឯកសារ ដើម្បីជៀសវាងព័ត៌មានស្ទួនគ្នា អនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំសម្គាល់ឃើញស្តង់ដា/បទប្បញ្ញត្តិផ្ទុយគ្នា និងស្នើដំណោះស្រាយ | បង្កើតឡើងដើម្បីជៀសវាងភាពស្ទួនគ្នា និងបទប្បញ្ញត្តិដែលផ្ទុយគ្នា |
| ភាពងាយស្រួលនៃការបង្កើត និងការអនុវត្ត | ផ្អែកលើទម្រង់ដែលមានស្រាប់ គោលការណ៍ណែនាំរបស់ទីភ្នាក់ងារ និងការកែលម្អជាគោលដៅនូវឯកសារដែលដាក់ទៅ EFSB | នឹងពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវ និងអភិវឌ្ឍយ៉ាងទូលំទូលាយ និងការអភិវឌ្ឍអន្តរភ្នាក់ងារ |
| ភាពមានប្រយោជន៍ដល់ទីភ្នាក់ងារផ្សេងទៀតសម្រាប់លក្ខខណ្ឌអនុញ្ញាតដែលបានណែនាំ និងការត្រួតពិនិត្យការអនុវត្ត | មានអត្ថប្រយោជន៍ខ្លាំងណាស់ ដោយសារព័ត៌មានត្រូវបានផ្តល់ជាទម្រង់ដែលធ្លាប់ស្គាល់ | មិនមានអត្ថប្រយោជន៍ដូចនេះទេ ដោយសារទីភ្នាក់ងារអាចជួបការលំបាកជាមួយនឹងទម្រង់ពាក្យសុំ និងការដាក់ឯកសារដែលមិនស្គាល់ |
| ការបន្តបច្ចុប្បន្នភាពជាមួយនឹងច្បាប់ គោលនយោបាយ និងកម្មវិធីថ្មីៗ | បន្តមានជាច្បាប់ បទប្បញ្ញត្តិ នាពេលបច្ចុប្បន្ន ហើយការអនុវត្តរបស់ទីភ្នាក់ងារវិវត្តប្រែប្រួល | នឹងតម្រូវឱ្យមានការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ |

# ការវាយតម្លៃគំរូនៃការដាក់ពាក្យសុំដោយបុគ្គលិក

| លក្ខណៈវិនិច្ឆ័យនៃការដាក់ពាក្យសុំ | ចំនួនសរុបនៃពាក្យសុំ | ការដាក់ពាក្យស្នើសុំដែលបង្កើតតាមគោលបំណង |
|---|---|---|
| លទ្ធផលមានប្រសិទ្ធភាព ទាន់ពេលវេលា និងគួរឱ្យជឿជាក់ | = | = |
| ការជៀសវាងព័ត៌មានស្ទួន/បទប្បញ្ញត្តិដែលផ្ទុយគ្នា | | ✓ |
| ភាពងាយស្រួលនៃការបង្កើត និងការអនុវត្ត | ✓ | |
| ភាពមានអត្ថប្រយោជន៍ដល់ទីភ្នាក់ងាររដ្ឋ និងមូលដ្ឋានផ្សេងទៀតសម្រាប់សកម្មភាពបញ្ចេញមតិ និងការអនុវត្ត | ✓ | |
| ការបន្តមានជាច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ និងកម្មវិធីបច្ចុប្បន្ន (ការធ្វើបច្ចុប្បន្នភាពដោយខ្លួនឯង) | ✓ | |
| តម្រូវការបុគ្គលិក | = | = |

# ការបង្កើតពាក្យសុំ៖ ស្តង់ដាសុខភាព សុវត្ថិភាព និងបរិស្ថាន

- ច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 តម្រូវឱ្យ EFSB បង្កើតស្តង់ដាកម្រិតមូលដ្ឋានរួមនៃសុខភាព សុវត្ថិភាព បរិស្ថាន និងស្តង់ដាសម្រាប់ការអនុញ្ញាតរួម។
- រហូតមកដល់បច្ចុប្បន្ន EFSB មិនបានកំណត់ស្តង់ដាលេខជាក់លាក់ដែលបង្កើតបានជាផលប៉ះពាល់ចំពោះបរិស្ថាន “ខាងអនុលោមភាព” ឬផលប៉ះពាល់ផ្សេងទៀត – ដោយមានករណីលើកលែងមួយចំនួន។
- EFSB ពឹងផ្អែកលើស្តង់ដាផ្សេងទៀតដែលកំណត់ដោយទីភ្នាក់ងារសហព័ន្ធ រដ្ឋ និងមូលដ្ឋាន ឬអង្គការកំណត់ស្តង់ដាផ្សេងទៀត (ឧទាហរណ៍ សមាគមការពារអគ្គិភ័យជាតិ)។
- បេក្ខជនជាសក្តានុពលសម្រាប់ស្តង់ដារបស់ EFSB៖ ផ្នែកដែនអេឡិចត្រូម៉ាញេទិក សម្លេងរំខាន ផែនការឆ្លើយតបគ្រោះមហន្តរាយ វិធានការភាពធន់នឹងអាកាសធាតុ ការប្រើប្រាស់ $SF_6$ វិធានការការពារទឹកក្រោមដី ជាដើម។

# ការបង្កើតពាក្យស្នើសុំ៖ ភាពសមស្របនៃទីតាំង ផលប៉ះពាល់រួម ការដាក់ពិន្ទុផ្លូវ/ទីតាំង

- EFSB តម្រូវឱ្យបង្កើតស្តង់ដាសម្រាប់ការអនុវត្តលក្ខណៈវិនិច្ឆ័យភាពសមស្របនៃទីតាំងដែលបង្កើតឡើងដោយផ្នែកវាយតម្លៃផលប៉ះពាល់បរិស្ថាន (EEA) ដើម្បីវាយតម្លៃ “ផលប៉ះពាល់សង្គម និងបរិស្ថាន” នៃ CEIF ដែលបានស្នើឡើង។
- ការិយាល័យយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថាន (“OEJE”) របស់ EEA ត្រូវបង្កើតស្តង់ដា និងគោលការណ៍ណែនាំសម្រាប់ឱ្យអ្នកដាក់ពាក្យសុំធ្វើការវិភាគផលប៉ះពាល់សរុប (“CIA”)។ EFSB នឹងបង្កើតស្តង់ដាដើម្បីអនុវត្តគោលការណ៍ទាំងនេះនៅក្នុងបទប្បញ្ញត្តិរបស់ខ្លួន។
- EFSB បានប្រើប្រាស់ប្រព័ន្ធដាក់ពិន្ទុផ្លូវ/ទីតាំងដោយផ្អែកលើកត្តាបរិស្ថាន និងវិស្វកម្មអស់រយៈពេលជាច្រើនឆ្នាំ ហើយអាចកែលម្អសម្រាប់ការប្រើប្រាស់នាពេលអនាគត។
- EFSB អាចស្វែងយល់ពីការរួមបញ្ចូលលក្ខខណ្ឌតម្រូវខាងលើ ទៅក្នុងដំណើរការដាក់ពិន្ទុថ្មី។ អាចរួមបញ្ចូលផលិតផលនេះនៅក្នុងបទប្បញ្ញត្តិ/ការណែនាំអំពីការដាក់ពាក្យ។

# ការបង្កើតពាក្យសុំ៖ បញ្ហាបច្ចេកវិទ្យាព័ត៌មាន

- ពាក្យស្នើសុំការអនុញ្ញាតរួមទំនងជានឹងមានចំនួនច្រើន អាចគ្របដណ្ដប់ការអនុញ្ញាតនីមួយៗដែលពីមុនចេញដោយទីភ្នាក់ងារផ្សេងគ្នាពី 10 ទៅ 20 ឬច្រើនជាងនេះ។
- EFSB និងភាគីពាក់ព័ន្ធត្រូវការវេទិកាបង្ហោះឯកសារ IT ដែលដំណើរការបានល្អ មុខងារសំខាន់ៗមួយចំនួនដែលត្រូវពិចារណា៖
  - ប្រព័ន្ធត្រូវតែអាចគ្រប់គ្រងឯកសារទំហំធំខ្លាំង។
  - តើប្រព័ន្ធអាចរួមបញ្ចូលផតថលមតិយោបល់ដែលបានអាប់ឡូតដោយអ្នកប្រើ (ដែលមិនត្រូវការការបង្ហោះដោយដៃដោយបុគ្គលិកភ្នាក់ងារ) ដែរឬទេ?
  - តើប្រព័ន្ធគួរផ្តល់ការជូនដំណឹងដោយស្វ័យប្រវត្តិទៅបញ្ជីសេវាកម្ម (កាលបរិច្ឆេទកំណត់គឺខិតជិតមកដល់) ដែរឬទេ?
  - ប្រព័ន្ធត្រូវតែមានសមត្ថភាពក្នុងការបញ្ជូនខ្លឹមសារឯកសារដែលបានផ្ទុកក្នុងផតប្រកបដោយប្រសិទ្ធភាពទៅ EFSB ដែលចាប់ផ្តើមជាពាក្យសុំលិខិតអនុញ្ញាតក្នុងមូលដ្ឋានរួមគ្នា ប្រសិនបើផ្ទេរដោយសាលាក្រុង ឬតាមការវិនិច្ឆ័យពីសេចក្តីសម្រេចការអនុញ្ញាតរួម។
- ផ្នែកព័ត៌មានវិទ្យាត្រូវការការសម្គាល់ដោយទីភ្នាក់ងាររដ្ឋផ្សេងទៀត
  - ត្រូវការសមត្ថភាពក្នុងការផ្ទេរព័ត៌មានកម្មវិធី EFSB ទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា ដែលប្រើដោយទីភ្នាក់ងារផ្តល់លិខិតអនុញ្ញាតផ្សេងទៀតសម្រាប់គោលបំណងអនុលោមភាព សារពើពន្ធ និងគោលបំណងផ្សេងទៀត។

# ការបង្កើតពាក្យស្នើសុំ៖ ការអនុម័តរបស់ EFSB ដើម្បីសាងសង់

- EFSB មិនមាន "ពាក្យស្នើសុំស្តង់ដា" សម្រាប់ "ការយល់ព្រមលើការសាងសង់" ជាមូលដ្ឋានរបស់ខ្លួនទេ។ ពាក្យស្នើសុំស្តង់ដារគួររួមបញ្ចូល៖
  - ទម្រង់ដែលមានរចនាសម្ព័ន្ធយ៉ាងល្អសម្រាប់ព័ត៌មានគម្រោងមូលដ្ឋាន
  - សេចក្តីសង្ខេបនៃដំណើរការដាក់ឯកសារជាមុន និងភស្តុតាងនៃការបញ្ចប់របស់វា
  - គោលការណ៍ណែនាំសម្រាប់ការបង្ហាញពីតម្រូវការ (ប្រសិនបើមាន) និងអត្ថប្រយោជន៍ថាមពល
  - ការពិពណ៌នាអំពីជម្រើសគម្រោង រួមទាំងបច្ចេកវិទ្យាបង្កើនកម្លាំងបណ្តាញអគ្គិសនី
  - ដំណើរការជ្រើសរើសផ្លូវ/ទីតាំងតាមការដាក់ពិន្ទុដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីតាំង ការវិភាគផលប៉ះពាល់សរុប និងសូចនាករផ្សេងទៀតដែលបានស្នើឡើងដោយ EFSB
  - ព័ត៌មានដែលមានរចនាសម្ព័ន្ធអំពីផលប៉ះពាល់បរិស្ថាន ថ្លៃចំណាយ ភាពជឿជាក់
  - ការអនុលោមតាមគោលការណ៍ថាមពល និងបរិស្ថានរបស់ Commonwealth
  - សំណើលើកលែងតំបន់ (ប្រសិនបើមាន)
  - វីដេអូទិដ្ឋភាពទូទៅនៃគម្រោង

# ភាពពេញលេញនៃសំណើ

- "ភាពពេញលេញ" នៃពាក្យស្នើសុំពីមន្ត្រីជាប្រធានត្រូវបានទាមទារក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីការដាក់ពាក្យ។ ការកំណត់ភាពពេញលេញចាប់ផ្តើមកំណត់ម៉ោងត្រួតពិនិត្យចាំបាច់ (ឬត្រូវការព័ត៌មានបន្ថែម)។
- ទិដ្ឋភាពសំខាន់ៗនៃការកំណត់ភាពពេញលេញ៖
  - EFSB នឹងស្វែងរក "អនុលោមភាពសំខាន់ៗ និងជាក់ច្បាស់" ជាមួយនឹងតម្រូវការព័ត៌មានទាំងអស់ដែលសមស្របសម្រាប់ការអនុញ្ញាតដែលបានស្នើសុំ។
  - អ្នកដាក់ពាក្យត្រូវតែសម្គាល់ការអនុញ្ញាតក្នុងស្រុក តំបន់ រដ្ឋ អាជ្ញាធរ ការយល់ព្រមដែលពាក់ព័ន្ធទាំងអស់ ដែលនឹងត្រូវបានទាមទារ។
  - អ្នកដាក់ពាក្យសុំនឹងត្រូវបានណែនាំឱ្យសម្គាល់ស្តង់ដាផ្ទុយគ្នា ប្រើស្តង់ដាតឹងរឹងជាងប្រសិនបើអាចធ្វើទៅបាន  ស្នើសុំការដោះស្រាយជម្លោះ។
  - EFSB នឹងស្វែងរកមតិចូលរួមរបស់ទីភ្នាក់ងាររដ្ឋ និងក្នុងតំបន់អំពីការកំណត់ភាពពេញលេញ។

# ថ្លៃដាក់ពាក្យសុំ

- ច្បាប់អាកាសធាតុឆ្នាំ 2024 បង្កើតយន្តការផ្តល់មូលនិធិថ្មីដើម្បីគាំទ្រដល់ការងាររបស់ EFSB និងមុខងារ DPU ដែលពាក់ព័ន្ធ។
  - ការវាយតម្លៃរហូតដល់ 0.1% លើក្រុមហ៊ុនចែកចាយអគ្គិសនីដើម្បីផ្តល់មូលនិធិដល់ប្រតិបត្តិការ និងការគ្រប់គ្រងទូទៅនៃផ្នែកកំណត់ទីតាំង តម្រូវការព័ត៌មានវិទ្យា និងអ្នកពិគ្រោះយោបល់សម្រាប់ការពិនិត្យឡើងវិញនៃ CEIF។
  - ការវាយតម្លៃប្រចាំឆ្នាំក្នុងចំនួនទឹកប្រាក់ $3.5 លានដុល្លារ លើសេវាផ្គត់ផ្គង់ឧស្ម័ន និងអគ្គិសនី ដើម្បីផ្តល់មូលនិធិដល់កម្មវិធីជំនួយគាំទ្ររបស់អន្តរការី។
  - ថ្លៃដាក់ពាក្យសុំត្រូវបានប្រកាសដោយបទប្បញ្ញត្តិសម្រាប់ការប្រើប្រាស់ដើម្បីគាំទ្រដល់មូលនិធិ EFSB Trust Fund និងកម្មវិធីជំនួយគាំទ្រអន្តរការីរបស់ EFSB/DPU។
  - បុគ្គលិក EFSB និង DPU កំពុងធ្វើការលើសំណើបទប្បញ្ញត្តិសម្រាប់ថ្លៃសំណើ។

# ការសម្របសម្រួលជាមួយ DOER

- ចំពោះ LCEIF ក្រុមប្រឹក្សា EFSB នឹងបង្កើតពាក្យសុំ ដែលដោះស្រាយបញ្ហាលិខិតអនុញ្ញាតក្នុងស្រុក បន្ថែមពីលើការអនុញ្ញាតរបស់រដ្ឋ។
- EFSB ក៏មានទំនួលខុសត្រូវពិនិត្យឡើងវិញសម្រាប់ការអនុញ្ញាតក្នុងស្រុករួមសម្រាប់ SCEIF ក្នុងករណីមួយចំនួន។
- DOER មានទំនួលខុសត្រូវចម្បងសម្រាប់ការបង្កើតពាក្យសុំ និងស្តង់ដាសម្រាប់ការស្នើសុំការអនុញ្ញាតរួមក្នុងមូលដ្ឋាន។
- EFSB និង DOER កំពុងពិភាក្សាថាតើត្រូវមានពាក្យស្នើសុំ និងស្តង់ដាស្រដៀងគ្នា ដែលអាចអនុវត្តបានចំពោះ SCEIF ដែរឬអត់ បើមិនដូចគ្នាទេ ដោយគិតទៅលើតួនាទីត្រួតស៊ីគ្នាចំពោះ SCEIF។
- EFSB និង DOER កំពុងសម្របសម្រួលយ៉ាងជិតស្និទ្ធ។

# បញ្ហាពាក្យស្នើសុំផ្សេងទៀត៖ ការលើកលែងការអនុញ្ញាតរបស់សហព័ន្ធ

- ច្បាប់អាកាសធាតុឆ្នាំ 2024 ចែងថាការអនុញ្ញាតរួមនឹងមិនរាប់បញ្ចូលការអនុញ្ញាតរបស់សហព័ន្ធដែល "ត្រូវបានផ្ទេរទៅភ្នាក់ងាររដ្ឋជាក់លាក់" ដូចដែលបានកំណត់ដោយក្រុមប្រឹក្សាកំណត់ទីតាំង។ ទោះជាយ៉ាងណាក៏ដោយ EFSB ប្រហែលជាអាចចេញលិខិតអនុញ្ញាតពីពាក្យសុំកម្រិតសហព័ន្ធប្រសិនបើវាផ្អែកលើស្តង់ដានៅក្នុងច្បាប់រដ្ឋ។ សូមមើលឧទាហរណ៍ វិញ្ញាបនបត្រគុណភាពទឹកផ្នែក 401។
- ពីដើមមក ការកំណត់នូវអ្វីដែលត្រូវបានដកចេញគឺជាបញ្ហាប្រឈមមួយ៖
  - នៅក្នុងគម្រោង Footprint Power អ្នកដាក់ពាក្យបានស្នើសុំការចេញលិខិតអនុញ្ញាតប្រើប្រាស់ខ្យល់ពីគោលការណ៍បង្ការការធ្លាក់ចុះគុណភាពខ្លាំង ("PSD") ដែលចេញដោយ EFSB ដោយធ្វើការអះអាងថាទីភ្នាក់ងារការពារបរិស្ថានរបស់អាមេរិកអនុញ្ញាតឱ្យ EFSB ចេញលិខិតអនុញ្ញាតនេះ។
  - MassDEP ជំទាស់ការបកស្រាយនេះ។ EFSB បានយល់ព្រមជាមួយ MassDEP ហើយមិនបានរួមបញ្ចូលការអនុញ្ញាត PSD ទេ។
- DFG (និងផ្នែកនេសាទ និងសត្វព្រៃរបស់ខ្លួន) បានលើកឡើងពីការព្រួយបារម្ភអំពីសិទ្ធិអំណាចសហព័ន្ធដែលបានផ្ទេរទៅក្រោមច្បាប់ប្រភេទសត្វដែលជិតផុតពូជនៃរដ្ឋ Massachusetts (“MESA”)។

# បញ្ហាសំណើផ្សេងទៀត៖ ការព្រួយបារម្ភអំពីពេលវេលា

- កាលបរិច្ឆេទផុតកំណត់ 12 ឬ 15 ខែសម្រាប់ការសម្រេចចិត្តចុងក្រោយរបស់ EFSB លើការអនុញ្ញាតរបស់រដ្ឋ និងស្រុក មានន័យថាការប្រមូលទិន្នន័យ និងការសិក្សានឹងត្រូវចាប់ផ្តើមឱ្យបានមុនកាលបរិច្ឆេទដាក់ពាក្យសុំ។
  - ការវាយតម្លៃធនធានអេកូឡូស៊ីជាច្រើន គឺពឹងផ្អែកលើទិន្នន័យរដូវកាលមួយចំនួន ហើយត្រូវធ្វើឡើងមុនពេលដាក់ពាក្យ។
  - ការសិក្សាបន្ថែមដោយសារតែការផ្លាស់ប្តូរគម្រោងបន្ទាប់ពីការដាក់សំណើអាចមិនសមស្របនឹងពេលវេលារបស់ EFSB ទេ។
- EFSB នឹងត្រូវបង្កើតយន្តការមួយចំនួន ដើម្បីដោះស្រាយការអនុញ្ញាតជាក់លាក់ ដែលមិនអាចបញ្ចូលក្នុងលិខិតអនុញ្ញាតរួមបញ្ចូលគ្នា ដោយសារទិន្នន័យ និងការវិភាគមិនពេញលេញ។
  - EFSB អាចពិចារណាលើបទប្បញ្ញត្តិកាត់ចេញ ឬចាត់ទុកជាការផ្លាស់ប្តូរគម្រោង។

# សំណួរ ចម្លើយ ការពិភាក្សា

# កិច្ចប្រជុំនឹងបន្តឡើងវិញនៅម៉ោង 3:05 p.m។

# ផ្ទាំងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត

https://www.mass.gov/info-details/efsb-permitting-dashboard

# វគ្គប្រជុំសម្រាប់ភាគីពាក់ព័ន្ធនាពេលខាងមុខ

- វគ្គប្រជុំទី 3 របស់ភាគីពាក់ព័ន្ធ (ថ្ងៃទី 24 ខែមេសា ម៉ោង **5:30-8:30 p.m.** Roxbury) ៖ **ការចូលរួមក្នុងការដាក់ឯកសារជាមុន កម្មវិធីជំនួយគាំទ្រអន្តរការី គោលការណ៍ណែនាំអំពីគម្រោងអត្ថប្រយោជន៍សហគមន៍**
  - លក្ខណៈហាយប្រ៊ីដ៖ មហាវិទ្យាល័យ Roxbury Community College បន្ទប់សិស្សទូទៅលេខ 3, 1234 Columbus Avenue, Roxbury, MA 02120
- វគ្គប្រជុំទី 4 របស់ភាគីពាក់ព័ន្ធ (ថ្ងៃទី 5 ខែឧសភា ម៉ោង **5:30-8:30 យប់** នៅ **Holyoke)** ៖ **ការវិភាគផលប៉ះពាល់រួម លក្ខណៈវិនិច្ឆ័យភាពសមស្របរបស់ទីតាំងគម្រោង**
  - លក្ខណៈហាយប្រ៊ីដ៖ Holyoke Heritage State Park, 221 Appleton Street, Holyoke, MA 01040

- https://www.mass.gov/climateact

# សំណួរ ចម្លើយ ការពិភាក្សាទូទៅ

www.mass.gov/climateact

sitingboard.filing@mass.gov (DPU/EFSB)
energypermitting@mass.gov (EEA)
doer.siting.permitting@mass.gov (DOER)